# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៤២

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូងបានបើកសនាវការស្តាប់សក្ខីកម្មបុគ្គលបីរូបផ្សេងៗគ្នាទាក់ទងនឹងការប្រព្រឹត្តមកលើក្រុមគោលដៅមួយចំនួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេស អតីតទាហាន លន់ នល់ និងជនជាតិភាគតិចវៀតណាម។ សប្តាហ៍នេះ បានចាប់ផ្តើមស្តាប់សាក្សីដំបូងគេ គឺលោក **សៅ វ៉ន** ជាអតីតប្រធានរណសិរ្ស នៅឃុំជាងទង ស្រុកត្រាំកក់។ សាក្សីលោក **សៅ វ៉ន** បានផ្តល់សក្ខីកម្មអំពីការប្រព្រឹត្តមកលើជនជាតិវៀតណាម និងអតីតមន្ត្រីរដ្ឋការ លន់ នល់ ដែលគាត់ធ្លាប់មានទំនាក់ទំនងខ្សែស្រឡាយផ្ទាល់ជាមួយនឹងបងប្រុសរបស់គាត់ដែលជាមន្ត្រីរដ្ឋការនៅក្នុងជួររដ្ឋាភិបាលនៃរបបសាធារណរដ្ឋខ្មែរ។ សាក្សីលោក **មាស វឿន** ក៏បានផ្តល់សក្ខីកម្មផងដែរ ស្តីពីការប្រព្រឹត្តមកលើក្រុមគោលដៅទាំងពីរនេះ តាមរយៈការយល់ឃើញរបស់គាត់ដែលធ្លាប់ធ្វើជាសមាជិកកងទ័ពបដិវត្តន៍កម្ពុជា។ សាក្សីចុងក្រោយ គឺអ្នកស្រី **អ៊ិន យឿន** បានវិលត្រឡប់ចូលរួមបញ្ចប់ការផ្តល់សក្ខីកម្មរបស់អ្នកស្រី នៅក្រោយពេលដែលបញ្ហាសុខភាពរបស់អ្នកស្រីបានធ្វើឲ្យខកខានការផ្តល់សក្ខីកម្មរបស់អ្នកស្រីកាលពីសប្តាហ៍មុនកន្លងទៅ។[1] មានភាពភាន់ច្រឡំមួយចំនួនបានកើតឡើង ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់អ្នកស្រី **អ៊ិន យឿន** ស្តីពីមូលហេតុនៃការបង្ហាញខ្លួនរបស់អ្នកស្រីនៅចំពោះមុខអង្គជំនុំជម្រះ ហើយប្រការនេះបានក្លាយជាភាពមិនច្បាស់លាស់ ថាតើអ្នកស្រីពិតជាបានផ្តល់សេចក្តីថ្លែងការណ៍

[1] សាក្សីអ្នកស្រី **អ៊ិន យឿន** បានផ្តល់សក្ខីកម្មនាពេលកន្លងមកនៅចំពោះមុខអង្គជំនុំជម្រះ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ សូមមើលរបាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម លេខ៤១ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍៣៨ (ចុះថ្ងៃទី២៥ ដល់ទី២៨ ខែមករា ឆ្នាំ២០១៦) ទំព័រ ៦។

ដែលត្រូវបានធ្វើឡើងដោយអ្នកស្រីផ្ទាល់ ឬក៏អត់។ បន្ថែមទៅលើការជំទាស់ជាច្រើនលើការប្រើប្រាស់ភស្តុតាងឲ្យបានត្រឹមត្រូវ អង្គជំនុំជម្រះក៏បានធ្វើការដោះស្រាយនូវបញ្ហានីតិវិធីមួយចំនួនតូច ពាក់ព័ន្ធនឹងការបង្ហាញខ្លួនរបស់សាក្សីអ្នកជំនាញ 2-TCE-95 នៅសប្តាហ៍បន្ទាប់ ស្តីពីការប្រព្រឹត្តមកលើជនជាតិចាម ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ អាឡិចសាន់ឌើ បេនហ្ស (Alexander Benz), ជា ប៊ូរ៉ាក់មុន្នី, ម៉ាលេនី ហៃដ៍ (Melanie Hyde), ខេតលីន កាហ្វហ្វ្រៀ (Caitlin McCaffrie), អេលីហ្សាប៊ែត អ័រ (Elizabeth Orr), ធី ស៊ុន (Thi Son), តាយលីណា និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (THE WSD HANDA Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University